# សារណារបស់ក្តីករុណា ចំពោះការអំពាវនាវឲ្យមានការចូលរួមគំនិត សម្រាប់មុខងារនៅសេសសល់របស់ អ.វ.ត.ក ទាក់ទងនឹងជនរងគ្រោះ

អស់រយៈពេលជាងមួយទសវត្សរ៍ហើយ ដែលក្តីករុណាបានអនុវត្តគម្រោងសំណង និងសកម្មភាពដទៃទៀត ដើម្បីគាំទ្រដល់ការចងចាំ និងការព្យាបាល ព្រមទាំងការយល់ដឹងទៅវិញទៅមក រវាងអ្នកនៅរស់ពីរបបខ្មែរក្រហម និងយុវជនជំនាន់ក្រោយ។ ក្នុងរយៈពេលរាប់ឆ្នាំមកហើយ ក្តីករុណាបានធ្វើការងារយ៉ាងស្វិតស្វាញជាមួយអ្នកនៅរស់ពីរបបខ្មែរក្រហម អតីតកម្មាភិបាលខ្មែរក្រហម សិស្សនិស្សិតតាមវិទ្យាល័យ និងសាកលវិទ្យាល័យ និងលោកគ្រូអ្នកគ្រូនៅតាមវិទ្យាល័យ។ មានការយកចិត្តទុកដាក់ជាពិសេស ទៅលើបញ្ហានៃអ្នកនៅរស់ពីឧក្រិដ្ឋកម្មផ្អែកលើយេនឌ័រនិងផ្លូវភេទ និងអ្នកនៅរស់ដែលមានប្រវត្តិជាជនជាតិអ៊ីស្លាម ឬជនជាតិវៀតណាម។

ក្រៅពីការចូលរួមក្នុងនីតិវិធីផ្លូវច្បាប់របស់ អ.វ.ត.ក ក៏មានការបង្កើតជាគំនិតផ្តួចផ្តើម ក្រៅផ្លូវតុលាការ ដើម្បីគាំទ្រដល់ការចងចាំ ការព្យាបាល និងសំណងចំពោះប្រជាជនកម្ពុជា។ ក្តីករុណាជឿជាក់ថា មានតម្រូវការយ៉ាងខ្លាំងនៅក្នុងសង្គមកម្ពុជា ដើម្បីបន្តដំណើរការទាំងអស់នេះ។ ដោយផ្អែកលើព័ត៌មាន និងការស្វែងយល់ដែលទទួលបាន តាមរយៈការចងក្រងប្រវត្តិសាស្ត្រដោយផ្ទាល់មាត់ជាច្រើន ការពិភាក្សាជាមួយក្រុមគ្រួសារនិងសហគមន៍នោះ ក្តីករុណាកំណត់បាននូវតម្រូវការដូចតទៅ នៅក្នុងសហគមន៍កម្ពុជា៖

. **តម្រូវការរបស់អ្នកនៅរស់ ដើម្បីចែករំលែកបទពិសោធន៍របស់ពួកគាត់**។ ដូចដែលអ្នកចូលរួមម្នាក់នៅក្នុងកិច្ចពិភាក្សាបានលើកឡើង៖ “ខ្ញុំនិយាយកាន់តែច្រើន ខ្ញុំកាន់តែធូរស្រាលក្នុងអារម្មណ៍”។ ការដែលអាចរៀបរាប់នូវរឿងរ៉ាវរបស់ពួកគាត់ និងត្រូវបានគេស្តាប់ដោយយកចិត្តទុកដាក់ គឺមានអានុភាពជួយព្យាបាល ប៉ុន្តែអ្នកនៅរស់បានបញ្ជាក់ថា ពួកគាត់មិនមានឱកាស ឬមានទីកន្លែងដើម្បីនិយាយបែបនេះឡើយ។

. អ្នកនៅរស់ជាច្រើន បានទទួលរងការឈឺចាប់ពីបទពិសោធន៍របស់ពួកគេដោយស្ងៀមស្ងាត់ ហើយអាកប្បកិរិយាដែលបណ្តាលពីការឈឺចាប់នេះ គឺយុវជនជំនាន់ក្រោយមិនអាចយល់បានឡើយ។ **ចាំបាច់ត្រូវមាន**

**ការលប់បំបាត់នូវគម្លាតនៃការយល់ដឹងនេះ** និងត្រូវមានការយល់ដឹងទៅវិញទៅមក រវាងអ្នកនៅរស់ និងអ្នកកើតជំនាន់ទីពីរនិងទីបី។

. **មានភាពចាំបាច់សម្រាប់យុវជន ក្នុងការកសាងសមត្ថភាពរបស់ពួកគេ ក្នុងការចាប់ផ្តើមការពិភាក្សា និងធ្វើការពិភាក្សា** អំពីអតីតកាលនៃរបបខ្មែរក្រហម ជាមួយអ្នកនៅរស់ នៅក្នុងគ្រួសារនិងសហគមន៍របស់ពួកគេ។ យុវជនមានចំណាប់អារម្មណ៍ ក្នុងការស្វែងយល់អំពីអតីតកាល ប៉ុន្តែពួកគេមានភាពស្ទាក់ស្ទើរ ក្នុងការសាកសួរសាច់ញាតិចាស់ៗ អំពីព្រឹត្តិការណ៍នេះ ដោយសារមូលហេតុផ្សេងៗគ្នា ដូចជាភាពមិនសមស្របបែបវប្បធម៌ ក្នុងការសាកសួរសំណួរ ឬដោយសារខ្លាចបណ្តាលឲ្យមានអារម្មណ៍មិនល្អ។

. អ្នកនៅរស់បង្ហាញអំពី **តម្រូវការឲ្យមានការដាក់រៀបចំ វត្ថុតំណាងការចងចាំ នៅតាមខេត្តរបស់ពួកគាត់** ដូចជាចេតិយ និងការចូលរួមរបស់យុវជន ក្នុងការថែរក្សាទីតាំងទាំងអស់នោះ ព្រមទាំងការថែរក្សាការចងចាំឲ្យនៅបន្ត។

. មាន **ការចង់បាននូវសំណងដោយផ្ទាល់ នៅកម្រិតបុគ្គល។** ក្រៅពីការបង្កើនកម្រិតជីវភាពរស់នៅ ការថែរក្សាផ្នែកវេជ្ជសាស្ត្រ និងចិត្តសង្គមហើយ អ្នកនៅរស់ក៏បង្ហាញពីការចង់បាន ក្នុងការជួសជុលដល់ផលវិបាលជាអវិជ្ជមាន ដល់កូនចៅជំនាន់ទីពីរ និងទីបី ដូចជាការគាំទ្រដល់ការសិក្សា និងភាពមានការងារធ្វើដែលល្អប្រសើរ។

. **តម្រូវការឲ្យមានការផ្តោតសំខាន់ លើការមិនត្រឡប់មកជាថ្មី ពីទស្សនៈរបស់ប្រជាជនតាមមូលដ្ឋាន។** ផ្តោតលើការអប់រំលើប្រវត្តិសាស្ត្រ និងការបណ្តុះបណ្តាលជំនាញទន់ ដើម្បីធានាថាជំនាញក្នុងការវិភាគជម្លោះ ដំណោះស្រាយ និងការទប់ស្កាត់ ត្រូវបានបណ្តុះទៅក្នុងសង្គមកម្ពុជា ហើយអាចជួយរួមចំណែកដល់ការទប់ស្កាត់កុំឲ្យប្រវត្តិសាស្ត្រកើតឡើងជាថ្មីម្តងទៀត។

. ទោះបីជាប្រវត្តិសាស្ត្រ (ដោយផ្ទាល់មាត់) ជាច្រើន ត្រូវបានប្រមូលផ្តុំក្តី **តែនៅមានតម្រូវការឲ្យចងក្រងបទពិសោធន៍ "លាក់កំបាំង" ជាច្រើនបន្ថែមទៀត** ដូចជាបទពិសោធន៍របស់ក្រុមភាគតិច (សាសនាពូជសាសន៍ ឬភេទ) និងបទពិសោធន៍របស់អតីតកម្មាភិបាលខ្មែរក្រហម ព្រមទាំងផលប៉ះពាល់/ឥទ្ធិពលទៅលើកូនចៅរបស់ពួកគាត់ នៅក្នុងពេលបច្ចុប្បន្ន។

. អ្នកនៅរស់ភាគច្រើនបានលើកឡើងអំពី **តួនាទីនិងការទទួលខុសត្រូវរបស់តួអង្គរដ្ឋ** ក្នុងការចូលរួមក្នុងសំណង ដូចជាប័ណ្ណសមធម៌ ប្រាក់សោធននិវត្តន៍ សេវាសាធារណៈផ្សេងទៀតសម្រាប់ពួកគាត់។

**សំណូមពរសម្រាប់កិច្ចអន្តរាគមន៍/សកម្មភាព/ការអនុវត្ត**

**១. កិច្ចពិភាក្សាអន្តរជំនាន់**

***ហេតុផល៖*** ផ្តោតលើការពិភាក្សា និងជំនាញប្រវត្តិសាស្ត្រផ្ទាល់មាត់ នៅក្នុងក្រុមគ្រួសារ និងសហគមន៍។ បង្កើតឱ្យមានទីកន្លែងសម្រាប់ការចែករំលែក ជាពិសេសឧក្រិដ្ឋកម្មផ្អែកលើយេនឌ័រ និងផ្លូវភេទ ការរើសអើងពូជសាសន៍ និងការកសាងជំនាញស្តាប់ដោយយកចិត្តទុកដាក់ (ការទំនាក់ទំនងដោយគ្មានភាពហឹង្សា) នឹងធានានូវដំណើរការព្យាបាលជាបន្ត នៅកម្រិតបុគ្គល និងកសាងជំនាញទប់ស្កាត់ (មិនកើតឡើងវិញ) របស់សហគមន៍

***ក្រុមគោលដៅ៖*** អ្នកនៅរស់ពីឧក្រិដ្ឋកម្មផ្អែកលើយេនឌ័រ និងផ្លូវភេទ ជនជាតិភាគតិច សិស្សនិស្សិត

***ពេលវេលា៖*** យ៉ាងតិចបីឆ្នាំ (២០២២-២០២៤)

**២. បង្កើតមជ្ឈមណ្ឌល សម្រាប់ការសម្របសម្រួល លើកិច្ចពិភាក្សា**

***ហេតុផល៖*** កសាងជំនាញសម្របសម្រួល លើការពិភាក្សារបស់បុគ្គលសំខាន់ៗនៅក្នុងសង្គមកម្ពុជា នឹងបង្កើតនូវអានុភាពធំ (*ripple-effect*) និងធានានូវនិរន្តរភាពនៃការចងចាំ និងដំណើរការព្យាបាល ព្រមទាំងការធ្វើការឈានទៅរកការមិនកើតឡើងវិញ។

***ក្រុមគោលដៅ៖*** អ្នកសម្របសម្រួលកិច្ចពិភាក្សានៅតាមសហគមន៍ លោកគ្រូអ្នកគ្រូនៅតាមវិទ្យាល័យ អាជ្ញាធរមូលដ្ឋាន

***ពេលវេលា៖*** យ៉ាងតិចបីឆ្នាំ (២០២២-២០២៤)

**៣. បន្តការចងក្រង និងថែរក្សាប្រវត្តិសាស្ត្រផ្ទាល់មាត់**

***ហេតុផល៖*** ប្រមូលរឿងរ៉ាវនៃបទពិសោធន៍ (ឧក្រិដ្ឋកម្មផ្អែកលើយេនឌ័រ និងផ្លូវភេទ ជនជាតិភាគតិច អតីតកម្មាភិបាលខ្មែរក្រហម) ដែលមិនទាន់រកឃើញនៅឡើយ។ ការនេះគឺមានសារសំខាន់ ចំពោះការរៀបរាប់ការពិត ពីគ្រប់ទិដ្ឋភាពទាំងអស់ (បង្កើតនូវរូបភាពទាំងស្រុង) ដែលនឹងក្លាយជាប្រភពដ៏សំខាន់ សម្រាប់ការស្រាវជ្រាវនាពេលអនាគត និងការសិក្សាអំពីអតីតកាលនៃរបបខ្មែរក្រហម។ នេះគឺដូចជាការកសាង/ប្រមូលផ្តុំប្រភពចម្បងសម្រាប់ការស្រាវជ្រាវ របស់អ្នកប្រវត្តិសាស្ត្រ (ឬអ្នកសង្គមវិទ្យា) នាអនាគត

***ក្រុមគោលដៅ៖*** ក្រុមអ្នកនៅរស់ ដែលមិនមានតំណាងគ្រប់គ្រាន់ អតីតកម្មាភិបាលខ្មែរក្រហម

***ពេលវេលា៖*** យ៉ាងតិចបីឆ្នាំ (២០២២-២០២៤)

### ៤. ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ

***ហេតុផល៖*** ក្នុងរបបខ្មែរក្រហម ការរស់នៅជាគ្រួសារ ត្រូវបានគាស់រំលើងចោល ហើយការអនុវត្តដូចជាការរៀបការដោយបង្ខំ បានបណ្តាលឲ្យមានស្ថានភាពអូសបន្លាយ នូវអំពើហឹង្សាក្នុងគ្រួសារ រួមទាំងអំពើហឹង្សាផ្លូវភេទ។ ក្រុមគ្រួសារធំ ដែលត្រូវប្រឈមជាមួយភាពតានតឹង និងអំពើហឹង្សា គឺរស់នៅក្រោមបន្ទាត់ក្រីក្រ ហើយកូនៗមិនអាចទទួលបានការអប់រំឲ្យបានគ្រប់គ្រាន់។ អ្នកនៅរស់ជាច្រើនបានលើកឡើង ពីតម្រូវការបណ្តុះបណ្តាលជំនាញគ្រឿងម៉ាស៊ីន និងកសិកម្មជាដើម ដើម្បីឲ្យយុវជនជំនាន់ក្រោយ អាចទទួលបានប្រាក់ចំណូល។

***ក្រុមគោលដៅ៖*** កូនចៅអ្នកនៅរស់

***ពេលវេលា៖*** យ៉ាងតិចបីឆ្នាំ (២០២២-២០២៤)

### ៥. ការថែរក្សាដោយខ្លួនឯងរបស់សហគមន៍ សម្រាប់អ្នកនៅរស់ពីឧក្រិដ្ឋកម្មផ្អែកលើយេនឌ័រ និងផ្លូវភេទ

***ហេតុផល៖*** ការប៉ះទង្គិច និងការគាំទ្រសុខភាពផ្លូវចិត្ត គឺនៅតែត្រូវការយ៉ាងខ្លាំង ក្នុងចំណោមអ្នកនៅរស់ពីឧក្រិដ្ឋកម្មផ្អែកលើយេនឌ័រ និងផ្លូវភេទ និងកូនៗរបស់ពួកគាត់ ប៉ុន្តែជាពិសេសនោះ គឺក្រុមគ្រួសារក្រីក្រ និង/ឬអ្នកនៅរស់ នៅក្នុងតំបន់ជនបទ ដែលការថែរក្សាសុខភាពផ្លូវចិត្តគ្រប់គ្រាន់ គឺមិនសូវមាន។ ដោយបណ្តុះបណ្តាលអ្នកសម្របសម្រួលតាមមូលដ្ឋាន ក្នុងការគាំទ្រសុខភាពផ្លូវចិត្ត សេវាកម្មដែលត្រូវការខ្លាំងទាំងអស់នេះ អាចត្រូវបានផ្តល់ជូនទៅអ្នកនៅរស់ ហើយក្នុងពេលជាមួយគ្នានោះ អាចកសាងភាពទប់ទល់របស់សហគមន៍។

*ក្រុមគោលដៅ៖* អ្នកនៅរស់ពីឧក្រិដ្ឋកម្មផ្អែកលើយេនឌ័រ និងផ្លូវភេទ និងសមាជិកគ្រួសារ អ្នកសម្របសម្រួលតាមមូលដ្ឋាន

*ពេលវេលា៖* យ៉ាងតិចបីឆ្នាំ (២០២២-២០២៤)

### ៦. ការស្រាវជ្រាវលើផលប៉ះពាល់ នៃការប៉ះទង្គិចដោយសារឧក្រិដ្ឋកម្មផ្អែកលើយេនឌ័រ និងផ្លូវភេទ ទៅលើកូនចៅ

*ហេតុផល៖* នៅក្នុងគម្រោងកន្លងមក អំពីការចងក្រងរឿងរ៉ាវ របស់អ្នកនៅរស់និងកូនៗរបស់ពួកគាត់ ក្ដីករុណាកត់សម្គាល់ពីលទ្ធផលគួរឲ្យចាប់អារម្មណ៍ គឺបទពិសោធន៍របស់ឪពុកម្ដាយ នឹងគ្របដណ្ដប់ទៅលើផ្នត់គំនិតរបស់កូនៗពួកគាត់។ លទ្ធផលបឋម នៃការផ្ទេរការប៉ះទង្គិច ឬផលប៉ះពាល់របស់ជំនាន់ទីពីរ ទាមទារឲ្យមានការស្រាវជ្រាវបន្ថែម។ តើបទពិសោធន៍នៃឧក្រិដ្ឋកម្មផ្អែកលើយេនឌ័រ និងផ្លូវភេទ របស់ឪពុកម្ដាយ ជះឥទ្ធិពលបែបណាដល់ការរស់នៅរបស់កូនៗពួកគាត់?

*ក្រុមគោលដៅ៖* អ្នកនៅរស់ និងកូនៗព្រមទាំងសមាជិកគ្រួសារពួកគាត់

*ពេលវេលា៖* ១២ខែ (២០២២-២០២៣)

### ៧. កិច្ចពិភាក្សារវាងអ្នកនៅរស់ និងតួអង្គរដ្ឋ

*ហេតុផល៖* ក្ដីករុណា និង UN WOMEN បានលើកឡើងនូវក្ដីបារម្ភមួយចំនួន ពីអ្នកនៅរស់ពីឧក្រិដ្ឋកម្មផ្អែកលើយេនឌ័រ និងផ្លូវភេទ ជូនទៅក្រសួងពាក់ព័ន្ធ ហើយបានរៀបចំកិច្ចពិភាក្សា រវាងអ្នកនៅរស់ ជាមួយក្រសួងនានា នៅក្នុងឆ្នាំ២០១៥។ ការបន្តនូវដំណើរការនេះ នឹងផ្ដល់នូវសារសំខាន់សម្រាប់អ្នកនៅរស់៖ ដោយមានតួអង្គស្ថាប័នរដ្ឋ ចូលរួមស្ដាប់តម្រូវការពិតប្រាកដរបស់ពួកគាត់ ព្រមទាំងបង្ហាញនូវតួនាទី និងការទទួលខុសត្រូវ ក្នុងការឆ្លើយតបចំពោះតម្រូវការរបស់ប្រជាជនខ្លួន។

*ក្រុមគោលដៅ៖* អ្នកនៅរស់ និងក្រសួងពាក់ពន្ធ

*ពេលវេលា៖* យ៉ាងតិចបីឆ្នាំ (២០២២-២០២៤)